ISSN 1810-6358

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

**Cambodia Development Resource Institute**

# របាយការណ៍ថ្មីៗស្តីពីសេដ្ឋកិច្ចកម្ពុជា

# Flash Report on the Cambodian Economy

កុម្ភៈ ២០០៨ / February 2008

ផាន់ ដាលីស / **Phann Dalis**

ប៉ុន ដូរីណា / **Pon Dorina**

ហ៊ីង វុត្ថា / **Hing Vutha**

ភីម រុនស៊ីណារិទ្ធិ / **Phim Runsinarith**

បកប្រែដោយ: យូ សិទ្ធីរិទ្ធ និង យេន សុផានី

ភ្នំពេញ កម្ពុជា

**Phnom Penh, Cambodia**

**TO SUBSCRIBE, PLEASE CONTACT:**

*Office Address:* #56, Street 315, Tuol Kork, Phnom Penh, Cambodia, *Postal Address:* CDRI, PO Box 622 Phnom Penh, Cambodia
*Tel:* (855-23) 881-384/881-701/881-916/883-603 *Fax:* (855-23) 880-734 *E-mail:* pubs@cdri.forum.org.kh. *Web site:* http://www.cdri.org.kh

# សកម្មភាពសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជា

# Main Economic Activities of Cambodia

នៅត្រីមាសទីបី ២00៧ គំរោងអនុម័តលើអនុវិស័យកាត់ដេរ កើនឡើងប្រហែល ៦៨% ធៀបនឹងត្រីមាសមុន ដល់ ៤0,៧ លានដុល្លារ។ ធៀបនឹងត្រីមាសទីបី ឆ្នាំ២00៦ អនុវិស័យនេះ កើន ៧៦%។

In the third quarter 2007, garment subsector approvals were up by approximately 68 percent from the preceding quarter, to USD 40.7 m. Compared to the same quarter in 2006, this subsector rose by 76 percent.

**Fixed Asset Investment Approvals by CDC for Garment Subsector**

2005 Q1 – 2007 Q3




*Including expansion projects.*
Source: Council for the Development of Cambodia

នៅខែវិច្ឆិកា ២00៧ ភ្ញៀវសរុបមកដល់កម្ពុជាកើន ២១% ធៀបនឹងខែមុន ដល់ ១៩៤.៦៤៦នាក់។ ភ្ញៀវមកដល់តាមផ្លូវអាកាស កើន ២៧% ដល់ ១៣0.៦៣0នាក់ ដែលក្នុងនោះ ៤១% ចុះនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។ ភ្ញៀវមកដល់តាមផ្លូវគោកកើន ៩,១% ដល់ ៥៨.៩៤១នាក់ និងមកតាមផ្លូវទឹក កើន ៦៨% ដល់ ៥0៧៥នាក់។ ភ្ញៀវមកសំរាកលំហែមាន ៨៤% នៃភ្ញៀវសរុប រីកើនប្រហែល ២៨% ធៀបនឹងខែមុន។

Total visitor arrivals to Cambodia increased by 21 percent from the preceding month to 194,646 in November 2007. Arrivals by air increased by 27 percent to 130,630, of which 41 percent was received by Phnom Penh airport. Arrivals by land were up by 9.1 percent to 58,941; and by water they rose by 68 percent to 5075. Holiday visitors made up 84 percent of total visitors, an increase of around 28 percent from the previous month.

**Cambodia: Foreign Visitor Arrivals**

September 2006 – November 2007




Source: Ministry of Tourism

នៅខែកញ្ញា ២00៧ គំរោងបានអនុម័តខាងវិស័យសាង់សង់នៅភ្នំពេញធ្លាក់ចុះយ៉ាងខ្លាំងដល់ទៅ ៩១% ធៀបនឹងខែមុន មកត្រឹម ៧,៦លានដុល្លារ។ ការអនុម័តលើសំណង់ផ្ទះល្វែង ថយចុះយ៉ាងខ្លាំង ៩៥% មកត្រឹម ៤,0លានដុល្លារ រីឯការអនុម័តសំណង់ភូមិគ្រឹះ និងផ្ទះ កើនឡើងជិតបីដងធៀបនឹងតំលៃខែមុន ដល់ ១,៥លានដុល្លារ។

In September 2007, Phnom Penh construction sector approvals decreased dramatically by 91 percent from the previous month to USD 7.6 m. Flat construction approvals fell sharply by 95 percent to USD 4.0 m, while villa and house approvals rose nearly to three times the value of the preceding month to USD 1.5 m.

**Phnom Penh: Value of Construction Approvals**

July 2006 – September 2007




Data was revised from June 2006 to date
Source: Economic & Monetary Statistics, NBC

# ថ្លៃទំនិញ និង អត្រាការប្រាក់លើប្រាក់កំចី

# Consumer Prices and Interest Rate on Bank Loan

យោងតាមទិន្នន័យផ្សាយចេញដោយវិទ្យាស្ថានជាតិស្ថិតិ ថ្លៃគោលរបស់សន្ទស្សន៍ថ្លៃទំនិញប្រែប្រួល ដូច្នេះរាល់ថ្លៃពីមុនទាំងអស់ក៏ត្រូវបានកែតំរូវឡើងវិញដែរ។ នៅខែធ្នូ ២០០៧ ព្រមជាមួយនឹងថ្លៃគោលថ្មី ថ្លៃទំនិញគ្រប់ប្រភេទនៅកម្ពុជា កើន ០,៤% ធៀបនឹងខែមុន។ ថ្លៃដឹកជញ្ជូនកើន ០,៧% រីឯថ្លៃម្ហូបអាហារ និងភេសជ្ជៈមិនមានជាតិអាកុល ធ្លាក់ចុះ ០,២% ។ នៅឆ្នាំ២០០៧ ថ្លៃទំនិញគ្រប់ប្រភេទទាំងអស់កើន ១០,៥% ដែលក្នុងនោះ ថ្លៃម្ហូបអាហារ និងភេសជ្ជៈមិនមានជាតិអាកុល កើន ១៤,៨% និង ថ្លៃដឹកជញ្ជូន កើន ១,៣% ។

Depending on data released by the National Institute of Statistics, base prices of the consumer price index have been changed; therefore, all the previous prices have also been revised accordingly. In December 2007 with the new base prices, Cambodia's all item prices increased by 0.4 percent from the previous month. Transportation costs rose by 0.7 percent, while food and non-alcoholic beverage prices declined by 0.2 percent. As of 2007, all item prices rose by 10.5 percent; food and non-alcoholic beverage prices increased by 14.8 percent, and transportation costs rose by 1.3 percent.

**Cambodia: Consumer Price Index**
(October–December 2006=100)
October 2006 – December 2007




Source: National Institute of Statistics

នៅខែមករា ២០០៨ ទាំងថ្លៃសាំង និងម៉ាស៊ូត នៅថេរមិនប្រែប្រួលទេ ធៀបនឹងខែមុន។ សាំងលក់ក្នុងតំលៃ ៤៤៧០រៀល/លីត្រ និង ម៉ាស៊ូតលក់ក្នុងតំលៃ ៣៨២០រៀល/លីត្រ។ ធៀបនឹងខែដូចគ្នា ២០០៧ ថ្លៃសាំងកើន ១៨% និង ថ្លៃម៉ាស៊ូតកើន ២៤%។

Both gasoline and diesel prices stayed stable in January 2008, compared to the previous month. Gasoline sold at 4470 riels/ℓ and diesel traded at 3820 riels/ℓ. Compared with the same month in 2007, the gasoline price rose by 18 percent and the cost of diesel increased by 24 percent.

**Phnom Penh: Gasoline & Diesel Prices**
November 2006 – January 2008




*revised data
Sources: CDRI and National Institute of Statistics

នៅខែតុលា ២០០៧ អត្រាការប្រាក់ចំពោះប្រាក់កំចីជារៀល ក្នុងរយៈ ១២ ខែគឺ ២៦,១៦% រីឯអត្រាការប្រាក់ចំពោះប្រាក់កំចីជាដុល្លារគឺ ១៥,៨៧%។ អត្រាការប្រាក់ចំពោះប្រាក់កំចីជារៀលកើន ០,១៤% ធៀបនឹងខែមុន រីឯ អត្រាការប្រាក់ចំពោះប្រាក់កំចីជាដុល្លារ ថយចុះ ០,០៣% ។ អត្រានេះ ត្រូវបានរាយការណ៍ដោយធនាគារមួយចំនួនចំណោមធនាគារទាំង ២៤។

The twelve-month interest rate on a riel loan was 26.16 percent in October 2007, while on a dollar loan it was 15.87 percent. The rate on a riel loan rose by 0.14 percent from the preceding month, while on a dollar loan it fell by 0.03 percent. The rate was reported by a number of banks among the 24 banks.

**Interest Rates on 12-Month Bank Loan**
August 2006 – October 2007




Source: Economic & Monetary Statistics, NBC

# ស្ថានភាពអត្រាប្តូរប្រាក់ និង ជំនួយអភិវឌ្ឍន៍ពីក្រៅប្រទេស

# Exchange Rates and External Development Assistance

នៅខែមករា ២០០៨ ប្រាក់រៀលឡើងថ្លៃ ០,១% ទល់នឹងដុល្លារUS ដោយប្តូរបាន ៣,៩៩៧រៀល/ដុល្លារUS ។ តំលៃប្រាក់រៀលកើនឡើង ១,៧% ធៀបនឹងខែដូចគ្នា ២០០៧ ។

In January 2008, the riel value appreciated by 0.1 percent against the US dollar, trading at 3,997 riels/USD. The value of riel further increased by 1.7 percent from the same month in 2007.

**Riels per US Dollar**
November 2006 – January 2008




Sources: National Bank of Cambodia and CDRI

ធៀបនឹងខែមុន តំលៃប្រាក់រៀល ថយចុះ ០,២% ទល់នឹងប្រាក់បាតថៃ និងប្រាក់ដុងវៀតណាម ។ នៅខែមករា ២០០៨ ប្រាក់រៀលទល់នឹងប្រាក់បាតថៃប្តូរបាន ១៣១,៦រៀល/បាតថៃ ហើយទល់នឹងប្រាក់ដុងវៀតណាម ប្តូរបាន ២៥,១រៀល/១០០ដុងវៀតណាម ។

Compared to the preceding month, the value of riel decreased by 0.2 percent against both the Thai baht and the Vietnamese dong. In January 2008, riel against the Thai baht exchanged at 131.6 riels/baht, and with the Vietnamese dong, traded at 25.1 riels per 100 dong.

**Riels per THB & VND**
November 2006 – January 2008




Source: CDRI

នៅឆ្នាំ ២០០៦ វិស័យកសិកម្មទទួលបាន ២៥,៩លានដុល្លារ ពីកញ្ចប់ថវិកាផ្តល់ពីក្រៅប្រទេសសំរាប់ការអភិវឌ្ឍ ។ ការបើកផ្តល់ថវិកានេះ ស្មើនឹង ៤,៤% នៃថវិកាសរុបសំរាប់ជំនួយអភិវឌ្ឍន៍ដល់កម្ពុជា។ ការបើកផ្តល់នេះ គឺដើម្បីកែលំអគោលនយោបាយនិងការគ្រប់គ្រងវិស័យកសិកម្ម ម្ហូបអាហារ/ដំណាំតាមរដូវ ដំណាំលក់យកប្រាក់និងដំណាំនាំចេញ ធនធានទឹកសំរាប់វិស័យកសិកម្ម និង អនុវិស័យពាក់ព័ន្ធដទៃទៀតដល់វិស័យកសិកម្ម ។

In 2006, the agriculture sector received USD 25.9 m from an external development disbursement package. This fund disbursement was 4.4 percent of the total funds for development assistance to Cambodia. The disbursement was for improving agriculture sector policy and management, food/seasonal crops, cash and export crops, agriculture water resources and other related subsectors to the agriculture sector.

**External Development Assistance Disbursement: Agriculture Sector** 2000 – 2006




Source: CDC, Cambodia Aid Effectiveness Report 2007

# ការអភិវឌ្ឍរូបិយវត្ថុ

# Monetary Developments

នៅខែវិច្ឆិកា ២០០៧ រូបិយវត្ថុទូទៅ (M2) កើនតាមអត្រាប្រចាំឆ្នាំ ១៤៩% ហើយរូបិយវត្ថុ (M1) កើនតាមអត្រាប្រចាំឆ្នាំ ១០៤% ។ ក្នុងរយៈ១២ខែដល់ខែវិច្ឆិកា ២០០៧ រូបិយវត្ថុទូទៅ (M2) កើន ៦០% ធៀបនឹងអត្រាកំនើន ៥២% ក្នុងរយៈ១២ខែដល់ខែតុលា ២០០៧ ។

In November 2007, liquidity (M2) grew at an annual rate of 149 percent and money (M1) increased at 104 percent annually. Over the past twelve months, liquidity (M2) grew by 60 percent, compared to the growth rate of 52 percent to October 2007.

**Monetary Survey**

September 2006 – November 2007




Source: National Bank of Cambodia

នៅខែវិច្ឆិកា ២០០៧ ឥណទានក្នុងស្រុក កើនតាមអត្រាប្រចាំឆ្នាំ ២១% និងឥណទានវិស័យឯកជន កើនតាមអត្រាប្រចាំឆ្នាំ ៦២% ។ ក្នុងរយៈ១២ខែដល់ខែវិច្ឆិកា ឥណទានក្នុងស្រុក កើន ៦០% ធៀបនឹងកំណើន ៦៣% ក្នុងរយៈមួយឆ្នាំដល់ខែតុលា។

Domestic credit rose at an annual rate of 21 percent and private sector credit grew annually by 62 percent in November 2007. Over the previous twelve months to November, domestic credit rose by 60 percent, compared to 63 percent growth in the year to October.

**Domestic Credit**

September 2006 – November 2007




Source: National Bank of Cambodia

នៅខែវិច្ឆិកា ២០០៧ ឥណទានវិស័យឯកជន កើន ៤,១% ធៀបនឹងខែមុន ដល់ ១០៧២៣,៧ពាន់លានរៀល និងឥណទានរដ្ឋាភិបាលកើន ០,១% ដល់ ២៩៧,២ពាន់លានរៀល។ ទ្រព្យសកម្មបរទេសសុទ្ធកើន ៧,៣% ដល់ ១០៥៤៥,៤ពាន់លានរៀល។ បំណុលធនាគារកើន ២,៨% ដល់ ៦០១៨,៩ ពាន់លានរៀល ក្នុងនោះប្រាក់បញ្ញើរដ្ឋាភិបាលកើន ៨,៧% ដល់ ២១០៥,៩ ពាន់លានរៀល និង ខ្ទង់ "ផ្សេងៗ" ថយចុះ ០,២% មកត្រឹម ៣៩១៣,១ ពាន់លានរៀល។ ប្រតិបត្តិការរូបិយវត្ថុនេះ បង្កើនរូបិយវត្ថុទូទៅបាន ៧,៩% ដល់ ១០៧២៣,៧ពាន់លានរៀល។

In November 2007, credit to the private sector increased by 4.1 percent from the previous month to KHR 10723.7 bn and claims on government rose by 0.1 percent to KHR 297.2 bn. Net foreign assets, further, rose by 7.3 percent to KHR 10545.4 bn. Bank liabilities, however, rose by 2.8 percent to KHR 6018.9 bn, of which government deposits increased by 8.7 percent to KHR 2105.9 bn and other items fell by 0.2 percent to KHR 3913.1 bn. This monetary operation increased liquidity by 7.9 percent to KHR 10723.7 bn.

**Monetary Operation**

September 2006 – November 2007




Source: National Bank of Cambodia

# ពាណិជ្ជកម្មក្រៅប្រទេស
# External Trade

នៅខែតុលា ២០០៧ ការនាំចេញសំខាន់ៗរបស់កម្ពុជា ធ្លាក់ចុះ ៦,០% ធៀបនឹងខែមុន មកត្រឹម ២៣៦,៨លានដុល្លារ។ សំលៀកបំពាក់ដែលជាផលិតផលនាំចេញសំខាន់មួយ ធ្លាក់ចុះ ៨,៤% មកត្រឹម ២១៤,៩លានដុល្លារ។ ការនាំចេញកៅស៊ូ ក៏ធ្លាក់ចុះដែរអស់ ១,៥% មកត្រឹម ៤,០លានដុល្លារ និងការនាំចេញត្រី ធ្លាក់ចុះ ១២% មកត្រឹម ០,៥លានដុល្លារ។

Cambodia's main exports dropped by 6.0 percent from the previous month to USD 236.8 m in October 2007. Garments, which are a main export product, fell by 8.4 percent to USD 214.9 m. Rubber exports, moreover, declined by 1.5 percent to USD 4.0 m and fish exports fell by 12 percent to USD 0.5 m.

**Cambodia: Main Exports**
August 2006 – October 2007




Source: *Economic & Monetary Statistics, Monthly Bulletin of NBC*

នៅខែតុលា ២០០៧ ការនាំចូលបារីថយចុះ ៤៧% ធៀបនឹងខែមុន មកត្រឹម ២៦,៥ពាន់លានរៀល រឺថយចុះ ៣៦% ធៀបនឹងខែដូចគ្នា ២០០៦។ ការនាំចូលស៊ីម៉ង់ត៍ថយចុះ ៣១% មកត្រឹម ១៤,៣ពាន់លានរៀល រីឯការនាំចូលដែកកើន ៣២% ដល់ ១៥,៤ពាន់លានរៀល។ ធៀបនឹងខែ ដូចគ្នា ២០០៦ ការនាំចូលស៊ីម៉ង់ត៍ និងដែក កើន ១១% និង ៥៩%។

In October 2007, cigarette imports decreased by 47 percent from the previous month to KHR 26.5 bn. This represents a decline of 36 percent from the value in the same month in 2006. Cement imports dropped by 31 percent to KHR 14.3 bn, while steel imports rose by 32 percent to KHR 15.4 bn. In comparison to the same month in 2006 cement and steel imports rose by 11 percent and 59 percent, respectively.

**Imports: Cigarettes & Construction Material**
August 2006 – October 2007




Source: *Economic & Monetary Statistics, Monthly Bulletin of NBC*

ការនាំចូលផលិតផលប្រេងកាតធ្លាក់ចុះ ១០% ធៀបនឹងខែមុនមកត្រឹម ៨០,១ពាន់លានរៀល។ ធៀបនឹងខែដូចគ្នាមួយឆ្នាំមុន តួលេខនេះ ធ្លាក់ចុះអស់ ៣៥%។

The value of petroleum product imports dropped by 10 percent from the preceding month to KHR 80.1 bn. This value, moreover, fell by 35 percent, compared to its value in same month last year.

**Imports: Petroleum Products**
August 2006 – October 2007




Source: *Economic & Monetary Statistics, Monthly Bulletin of NBC*

# ការអនុវត្តន៍ថវិកាជាតិ

# National Budget Operations

នៅខែកក្កដា ២០០៧ ថវិការចរន្តរបស់រដ្ឋាភិបាលមានអតិរេក ៣៥,៥ពាន់លានរៀល រឺ ៦៧% តិចជាងខែមុន។ ធៀបនឹងខែដូចគ្នាមួយឆ្នាំមុន អតិរេកថយចុះ ២៩%។

The government's current budget surplus in July 2007 was KHR35.5 bn, 67 percent less than in the previous month. Compared to the same month a year earlier, the surplus decreased by 29 percent.

**Current Budget Operations**

February 2006–July 2007




*Note: Provisional for 2007.*
Source: *Monthly Bulletin of Statistics* (MEF web site )

នៅខែកក្កដា ២០០៧ ចំណូលថវិការចរន្តសរុបមាន ៣២០,១ពាន់លានរៀល រឺ ធ្លាក់ចុះ ៥,៩% ធៀបនឹងខែមុន។ ចំណូលពន្ធក្នុងស្រុកធ្លាក់ចុះ ១៧% មកត្រឹម ១៧៧,១ពាន់លានរៀល ចំណូលពន្ធនាំចេញ-នាំចូល ធ្លាក់ចុះ ២៦% មកត្រឹម ៦៦,៨ពាន់លានរៀល ចំណូលមិនមែនពន្ធ កើនមួយជាពីរដល់ ៧៦,២ពាន់លានរៀល។

In July 2007, government current revenue totalled KHR320.1 bn, a decline of 5.9 percent from the preceding month. Domestic tax revenue decreased by 17 percent to KHR177.1 bn; revenue from import and export taxes dropped by 26 percent to KHR66.8 bn; revenue from non-tax sources doubled to KHR76.2 bn.

**Current Budget Revenue**

February 2006–July 2007




*Note: Provisional for 2007.*
Source: *Monthly Bulletin of Statistics* (MEF web site )

នៅខែកក្កដា ២០០៧ ចំណាយថវិការចរន្តរបស់រដ្ឋាភិបាលកើន ២២% ធៀបនឹងខែមិថុនា ដល់ ២៨៤,៦ពាន់លានរៀល។ ចំណាយលើបៀវត្សរ៍មានចំនួន ១០៦,៨ពាន់លានរៀល រឺកើន ៣៦% រីឯចំណាយលើឧបត្ថម្ភធន និងជំនួយសង្គម ធ្លាក់ចុះ ១៥% មកត្រឹម ៥៤,៨ពាន់លានរៀល។

Government current budget expenditure increased by 22 percent from June to KHR284.6 bn in July 2007. Wages accounted for KHR106.8 bn, a rise of 36 percent, while spending on subsidies and social assistance fell by 15 percent to KHR54.8 bn.

**Current Budget Expenditure Components**

February 2006–July 2007




*Note: Provisional for 2007.*
Source: *Monthly Bulletin of Statistics* (MEF web site )

# សកម្មភាពសេដ្ឋកិច្ចនៃបណ្ដាប្រទេសជាដៃគូរបស់កម្ពុជា

# Economic Activity of Selected Economic Partners of Cambodia

នៅខែធ្នូ ការនាំចេញទំនិញរបស់ US និង ជប៉ុន កើនឡើង រីឯការនាំចេញទំនិញរបស់តំបន់អឺរ៉ូ ថយចុះ។ ការនាំចេញទំនិញរបស់ US កើន ២,១% ធៀបនឹងខែមុន ដល់ ១០៣,០៨ពាន់លានដុល្លារ និងការនាំចេញទំនិញរបស់ជប៉ុន កើន ៥,២% ដល់ ៦៧,២៨ពាន់លានដុល្លារ។ រីឯការនាំចេញទំនិញរបស់តំបន់អឺរ៉ូ ធ្លាក់ចុះ ៥,២% ធៀបនឹងខែមុន មកត្រឹម ១៧៩,៨៦ ពាន់លានដុល្លារ។

In December, goods exports of the US and Japan increased, while goods export of the Euro zone decreased. US goods exports rose by 2.1 percent from the previous month to USD103.08 bn, and goods exports of Japan increased by 5.2 percent to USD67.28 bn. Goods exports of Euro zone fell by 5.2 percent from the previous month to USD179.86 bn.

**Goods Exports: US, Euro zone & Japan**
December 2006 – December 2007




Sources: BEA, Eurostat and OECD

នៅខែធ្នូ ប្រទេសចិនមានអតិរេកពាណិជ្ជកម្ម ២២,៦៩ពាន់លានដុល្លារ ធៀបនឹងអតិរេក ២៦,២៨ពាន់លានដុល្លារ នៅខែវិច្ឆិកា។ ការនាំចេញសរុបថយចុះ ២,៧% ធៀបនឹងខែមុន មកត្រឹម ១១៤,៤២ពាន់លានដុល្លារ រីឯការនាំចូលសរុបកើន ០,៤% ដល់ ៩១,៧៣ពាន់លានដុល្លារ។

In December, China recorded a trade surplus of USD22.69 bn, compared to USD26.28 bn in November. Total exports decreased by 2.7 percent from the previous month to USD114.42 bn, while total imports rose by 0.4 percent to USD91.73 bn.

**External Trade: China**
December 2006 – December 2007




Sources: National Bureau of Statistics of China

នៅខែធ្នូ ប្រទេសម៉ាឡេស៊ីមានអតិរេកពាណិជ្ជកម្ម ២,៩០ពាន់លានដុល្លារ ធៀបនឹងអតិរេក ៣,១០ពាន់លានដុល្លារ នៅខែវិច្ឆិកា ។ ការនាំចេញកើន ១,៣% ធៀបនឹងខែមុន ដល់ ១៦,៣៥ពាន់លានដុល្លារ ហើយការនាំចូលកើន ៣,២% ដល់ ១៣,៤៥ពាន់លានដុល្លារ។

In December, Malaysia recorded a trade surplus of USD2.90 bn, compared to USD3.10 bn in November. Exports rose by 1.3 percent from the previous month to USD16.35 bn., and imports increased by 3.2 percent to USD13.45 bn.

**External Trade: Malaysia**
December 2006 – December 2007




Source: Department of Statistics, Malaysia

# ស្ថានភាពអត្រាអតិផរណានៃបណ្តាប្រទេសដៃគូរបស់កម្ពុជា

# Inflation Rates in Selected Economic Partners of Cambodia

ថ្លៃទំនិញប្រើប្រាស់នៅ US កើន ៤,១% ក្នុងរយៈមួយឆ្នាំដល់ខែធ្នូ ២០០៧។ យោងតាមក្រសួងការងាររបស់ US កំណើននេះបណ្តាលជាសំខាន់មកពីការឡើងថ្លៃម្ហូបអាហារ ការថែទាំសុខភាព ដឹកជញ្ជូន និងថាមពល។ អំឡុងពេលដូចគ្នានេះ អតិផរណា មានអត្រា ៣,១% នៅតំបន់អឺរ៉ូ និង ០,៧% នៅជប៉ុន។

US consumer prices rose by 4.1 percent in the year to December 2007. According to the US Department of Labor, this increase largely reflected higher charges for food, medical care, transportation and energy. During the same period, inflation was 3.1 percent in the Euro zone and 0.7 percent in Japan.

**Inflation Rates: US, Euro zone & Japan**
(Price change from a year earlier)




*Note: The latest data available for December 2007.*
Sources: IMF and *The Economist* (16 February 2008)

ថ្លៃទំនិញប្រើប្រាស់នៅហុងកុង កើន ៣,៨% ក្នុងរយៈមួយឆ្នាំដល់ខែធ្នូ ២០០៧។ នេះបណ្តាលជាសំខាន់មកពីការកើនឡើងយ៉ាងខ្លាំងនៃថ្លៃសាច់ជ្រូក ខ្សែទស្សនៈកិច្ច និងថ្លៃម្ហូបអាហារខាងក្រៅផ្ទះ។ អំឡុងពេលដូចគ្នានេះ ថ្លៃទំនិញប្រើប្រាស់នៅប្រទេសចិន និង កូរ៉េខាងត្បូង កើន ៦,៥% និង ៣,៦%។

Hong Kong’s consumer prices rose by 3.8 percent in the year to December 2007. This was mainly due to substantial increases in the prices of pork, charges in package tours and cost of meals bought away from home. During the same period, consumer prices in China and South Korea increased by 6.5 percent and 3.6 percent, respectively.

**Inflation Rate: China, Hong Kong & South Korea**
(Price change from a year earlier)




*Note: The latest data available are for December 2007.*
Sources: IMF and *The Economist* (16 February 2008)

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅសិង្ហបុរី កើន ៤,៤% ក្នុងរយៈមួយឆ្នាំដល់ខែធ្នូ ២០០៧។ នាយកដ្ឋានស្ថិតិសិង្ហបុរី សន្មតថាកំនើននេះបណ្តាលមកពីការឡើងថ្លៃម្ហូបអាហារ ការដឹកជញ្ជូននិងទូរគមនាគមន៍ និងការថែទាំសុខភាព។ អំឡុងពេលដូចគ្នា អតិផរណាពីមួយឆ្នាំទៅមួយឆ្នាំ មានអត្រា ២,៤% នៅម៉ាឡេស៊ី និង ៣,២% នៅថៃ។

Singapore's consumer price index rose by 4.4 percent in the year to December 2007. The Department of Statistics of Singapore attributed this to higher costs for food, transport and communication and health care. During the same period, the year-on-year inflation rate was 2.4 percent in Malaysia and 3.2 percent in Thailand.

**Inflation Rate: Selected ASEAN Countries**
(Price change from a year earlier)




*Note: The latest data available are for December 2007.*
Sources: IMF and *The Economist* (16 February 2008)

# អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ
# Exchange Rates in World Markets

នៅខែកុម្ភៈ ២០០៨ ចលនាប្រាក់ដុល្លារ US មានការប្រែប្រួលឡើងចុះទល់នឹងរូបិយវត្ថុចំបងៗ។ ទល់នឹងប្រាក់អឺរ៉ូ វាប្តូរបាន ០,៦៨អឺរ៉ូ/ដុល្លារUS រឺធ្លាក់ថ្លៃ ០,២% ធៀបនឹងខែមុន។ ទល់នឹងប្រាក់យ៉េនជប៉ុន វាប្តូរបាន ១០៧,១ យ៉េន/ដុល្លារUS រឺ ធ្លាក់ថ្លៃ ០,៨%ធៀបនឹងខែមុនដែរ។ ដុល្លារ US ធ្លាក់ថ្លៃទល់នឹងប្រាក់អឺរ៉ូ និងប្រាក់យ៉េន ដោយសារការវាយស្មានថាធនាគារកណ្តាលUS នឹងបន្តបន្ទាបអត្រាការប្រាក់គោលរបស់វាពី ៣%ចុះ។

In February 2008, the movement of US dollar was mixed against most major currencies. Against the euro, it traded at 0.68 EUR/USD, a 0.2 percent fall from a month earlier. It bought 107.1 Japanese yen, a 0.8 loss from January 2008. The U.S. currency declined against the euro and the yen on speculation that the Federal Reserve will keep cutting its benchmark interest rate from 3 percent.

**EUR & JPY per USD**
Feb 07 – Feb 08 (monthly average)




Source: Federal Reserve Bank of New York

នៅខែកុម្ភៈ ២០០៨ ប្រាក់វ៉ុនកូរ៉េខាងត្បូងប្តូរបាន ៩៤៣,៩៧វ៉ុន/ដុល្លារUS រឺធ្លាក់ថ្លៃ ០,២% ធៀបនឹងខែមករា។ ប្រាក់វ៉ុនដែលជារូបិយប័ណ្ណមានដំណើរការអន់ជាងគេបំផុតទីពីរ ក្នុងចំណោមរូបិយប័ណ្ណមានដំណើរការខ្លាំងទាំង១៦ បានចេញផ្សាយការខាតបង់មួយ ដោយសារអ្នកវិនិយោគទុនបរទេស បន្តការលក់បន្ថែមនូវប័ណ្ណភាគហ៊ុនរបស់កូរ៉េ។ អំឡុងពេលដូចគ្នានេះ ដុល្លារហុងកុងមានដំណើរការឈានមុខតិចតួចទល់នឹងដុល្លារUS ដោយវាប្តូរបាន ៧,៨០ដុល្លារហុងកុង/ដុល្លារUS រឺឡើងថ្លៃ ០,១% ធៀបនឹងខែមុន។

In February 2008, the South Korean won exchanged at 943.97 per US dollar, a 0.2 percent depreciation from January. The won, which is the second worst performer of the 16 most active currencies, posted a loss as overseas investors added to sales of the nation’s shares. During the same period, the Hong Kong dollar advanced slightly against its US counterpart, trading at 7.80 per USD, a 0.1 percent gain from a month earlier.

**KRW & HKD per USD**
Feb 07 – Feb 08 (monthly average)




Source: Federal Reserve Bank of New York

នៅខែមករា ដុល្លារសិង្ហបុរីឡើងថ្លៃទល់នឹងដុល្លារUS ដោយប្តូរបាន ១,៤១១ដុល្លារសិង្ហបុរី/ដុល្លារUS ធៀបនឹងខែមុន ១,៤៣១ដុល្លារសិង្ហបុរី/ដុល្លារUS។ អាជ្ញាធររូបិយវត្ថុរបស់សិង្ហបុរី នឹងបន្តអនុញ្ញាតអោយមានការឡើងថ្លៃរូបិយវត្ថុក្នុងល្បឿនមួយសមស្រប រហូតដល់ភាពមិនប្រាកដនានាលើហានិភ័យកំណើនសកលលោក អាចកាត់បន្ថយបាន។ អំឡុងពេលដូចគ្នា ប្រាក់បាតថៃធ្លាក់ថ្លៃ ដោយវាប្តូរបាន ៣០,២៩បាត/ដុល្លារUS។

In January, the Singapore dollar appreciated against the US dollar, trading at 1.411 SGD/USD compared to 1.431 SGD/USD a month earlier. The Monetary Authority of Singapore will continue to allow only a modest pace of appreciation in the currency until uncertainties over global growth risks diminish. During the same period, the Thai baht depreciated, exchanging at 30.29 per US dollar.

**THB & SGD Per USD**
Feb 07 – Feb 08 (monthly average)




Source: Federal Reserve Bank of New York

# ស្ថានភាពតំលៃទំនិញលើទីផ្សារអន្តរជាតិ

# Commodity Prices in World Markets

នៅខែមករា ២០០៨ ថ្លៃអង្ករពិភពលោក កើនឡើងយ៉ាងខ្លាំង ដោយសារតំរូវការនាំចូលខ្លាំង។ សន្ទស្សន៍ថ្លៃអន្តរជាតិ (IPO) គឺ ១៧២,៧ពិន្ទុ ធៀបនឹង ១៦៣,៧ ពិន្ទុ នៅខែធ្នូ ២០០៧។ នៅថៃ ថ្លៃអង្ករថៃ ១០០% B កើន ៤,៨% ធៀបនឹងខែមុន ដល់ ៣៥៩,១៧ដុល្លារ/តោន។ នៅ US ថ្លៃអង្ករនាំចេញកើន ៣,៣% ធៀបនឹងខែមុន ដល់ ៤៨៨,៨៧ដុល្លារ/តោន។

In January 2008, world rice prices increased sharply due to strong import demand. The International Prices Index (IPO) was 172.7, compared to 163.7 in December 2007. In Thailand, the price of Thai 100%B rose by 4.8 percent from the previous month to USD359.17 per tonne. In the United States, the export price rose by 3.3 percent from the previous month to USD488.87 per tonne.

**Rice: International Prices Index & Export Prices**

December 2006 – December 2007




Sources: Osiriz/InfoArroz and InterRice.

នៅខែមករា ២០០៨ ថ្លៃសណ្តែកសៀង ពោត និង ប្រេងឆា កើនឡើង។ សណ្តែកសៀងលក់ក្នុងតំលៃ ៤២៧,៤៣ដុល្លារ/តោន រីឡើងថ្លៃពី ៣៩១,១៣ដុល្លារ/តោន នៅខែធ្នូ ២០០៧។ ពោតលក់ថ្លៃ ១៨៤,៣០ ដុល្លារ/តោន រីឡើងថ្លៃ ១៣% ធៀបនឹងខែមុន។ ថ្លៃប្រេងឆា កើនឡើង ១១,៥% ធៀបនឹងខែមុន ដល់ ៩៦០,៥១ដុល្លារ/តោន។

In January 2008, the prices of soybeans, maize and palm oil increased. Soybeans sold at USD427.43 per tonne, up from USD391.13 per tonne in December 2007. Maize was USD184.30 per tonne, a 13 percent increase from the previous month. The price of palm oil increased by 11.5 percent from the previous month to USD960.51 per tonne.

**Prices: Soybeans, Maize & Palm Oil**

January 2007 – January 2008




Source: Food and Agriculture Organisation (FAO)

នៅខែមករា ២០០៨ ថ្លៃប្រេងឆៅ សាំង និង ម៉ាស៊ូត កើនឡើង។ ថ្លៃប្រេងឆៅលក់ដល់ដៃរបស់ OPEC គឺ ៨៩,៩៦ដុល្លារ/ធុង ធៀបនឹង ៨៨,០២ ដុល្លារ/ធុង នៅខែធ្នូ ២០០៧។ នៅ US Gulf Coast ថ្លៃសាំងធម្មតា (អុកតាន ៨៧%) កើន ៣,៧% ធៀបនឹងខែមុន ដល់ ៦១,០៩សេន/លីត្រ។ ម៉ាស៊ូត (មានលាយស្ពាន់ធ័រតិចលេខ២) កើន ០,១% ធៀបនឹងខែមុន ដល់ ៦៧,១៤ សេន/លីត្រ។

In January 2008, the prices of crude oil, gasoline and diesel increased. The OPEC spot price of crude oil was USD89.96 per barrel, against USD88.02 in December 2007. Regular gasoline (87 octane) prices on the US Gulf Coast rose by 3.7 percent from the previous month to 61.09 cents per litre. Diesel (Low Sulphur No.2) on the US Gulf Coast increased by 0.1 percent from the previous month, to 67.14 cents per litre.

**Prices: Crude Oil, Gasoline & Diesel**

January 2007 – January 2008




Source: US Energy Information Administration

# ព័ត៌មានសេដ្ឋកិច្ច
# Economic News

**ប្រទេសកម្ពុជា ស្តារជួសជុលឡើងវិញនូវខ្សែរថភ្លើងប្រវត្តិសាស្ត្រ:** ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និង រាជរដ្ឋាភិបាលកម្ពុជា រួមសហការគ្នាស្តារជួសជុលឡើងវិញនូវផ្លូវដែកប្រវែងប្រហែល ៦០០គ.ម ដែលតភ្ជាប់ពីកម្ពុជាទៅថៃ ក្នុងអំឡុងពីរឆ្នាំខាងមុខ ។ លោក Haruhiko Kuroda នាយក ADB បានលើកឡើងក្នុងពិធីមួយ នៅស្រុកសិរីសោភ័ណ ប្រទេសកម្ពុជា ថា "នេះជាជំហានចុងក្រោយមួយនៃការបង្កើតផ្លូវរថភ្លើងក្នុងតំបន់ ដែលលាតសន្ធឹងពីសិង្ហបុរី ទៅប៉េកាំង ។ ក្នុងពេលឆាប់ៗនេះ រថភ្លើងនឹងធ្វើដំណើរពីប្រទេសសិង្ហបុរីទៅក្រុងព្រះសីហនុ" ។ ផ្លូវរថភ្លើង ៤៨គ.ម ផ្សេងទៀតដែលនៅជិតទល់ដែនថៃ ក៏នឹងស្តារជួសជុលឡើងវិញដែរក្រោមការផ្តួចផ្តើមគំនិតនេះ ។ គំរោងស្តារជួសជុលផ្លូវរថភ្លើងកម្ពុជា ទទួលមូលនិធិ ៤២លានដុល្លារពីកំចីសម្បទានរបស់ ADB ។ អាជ្ញាធរ នឹងតែងតាំងប្រតិបត្តិកររថភ្លើងអន្តរជាតិមួយដើម្បីដំណើរការ ជួសជុលថែទាំ និងវិនិយោគលើផ្លូវដែក ក្នុងអំឡុងពេល ៣០ឆ្នាំខាងមុខ។ ការធ្វើអោយប្រសើរឡើងនេះ មិនគ្រាន់តែធ្វើអោយផ្លូវរថភ្លើងកម្ពុជាមានសកម្មភាពឡើងវិញប៉ុណ្ណោះទេ ប៉ុន្តែនឹងជួយជំរុញពាណិជ្ជកម្មតាមរយៈការកាត់បន្ថយចំណាយដឹកជញ្ជូនទៀតផង ។ លើសពីនេះ ផ្លូវដែកក៏នឹងជួយកាត់បន្ថយការស្ទះចរាចរណ៍តាមផ្លូវថ្នល់នៅកម្ពុជាថែមទៀត ។ គំរោងនេះ គឺជាសមាសធាតុសំខាន់បំផុតនៃច្រករបៀងភាគខាងត្បូង ក្នុងមហាអនុតំបន់មេគង្គ ដែលតភ្ជាប់ប្រទេសថៃ កម្ពុជា និង វៀតណាម ។

***Cambodia to restore its historic rail links:*** The Asian Development Bank (ADB) and the Royal Government of Cambodia will be working together to restore around 600 kilometres of rail track between Thailand and Cambodia over the next two years. “This is one of the last steps in the creation of a regional railway that will stretch from Singapore to Beijing,” said ADB President Haruhiko Kuroda at a ceremony in Sisophon, Cambodia. “Soon, trains will be running from Singapore to Sihanoukville.” Another 48 kilometres of track near the Thai border will also be restored under the initiative. Cambodia’s railway rehabilitation project will be funded by a $42 million concessional loan from the ADB. The authority will also appoint an international railway operator to operate, maintain and invest in the railway over the next 30 years. The upgrade will not only revitalise Cambodia’s railways, but also enhance trade through reduced transport costs. The railway will also help ease traffic on Cambodia’s roads. The project forms a vital component of the Greater Mekong Subregion’s southern corridor, which links Thailand, Cambodia and Vietnam. (Cited from etravelblackboardasia.com, 25 February 2008)